ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការក្រសួងយុត្តិធម៌**
លេខ ១១៤៩ អក.កយ/២០០៤

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ជម្រាបមក</u>**

## លោកប្រធានតុលាការក្រុងភ្នំពេញ
## លោកព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ

**<u>សូមជ្រាប</u>**

**<u>កម្មវត្ថុ:</u>** អំពីការឃុំខ្លួនពិរុទ្ធជនហួសថេរវេលាកំណត់នៃច្បាប់ និងការយឺតយ៉ាវក្នុងការផ្តល់សាលក្រម សាលដីកា ស្ថាពរ ទៅពន្ធនាគារ ។

**<u>យោង:</u>** របាយការណ៍ ចុះថ្ងៃទី០៦-០៩-២០០៤ របស់គណៈប្រតិភូរបស់ក្រសួងយុត្តិធម៌ ។

ខ្ញុំសូមជម្រាបលោកជ្រាបថា គណៈប្រតិភូរបស់ក្រសួងយុត្តិធម៌បានចុះទំនាក់ទំនងការងារជាមួយស្ថាប័នអយ្យការ និងមន្ត្រីពន្ធនាគារ កាលពីថ្ងៃទី៣១-០៨-២០០៤ បានទទួលសេចក្តីរាយការណ៍ថា តុលាការក្រុងភ្នំពេញ ចាប់ពីថ្ងៃទី០១-០១-២០០៤ ដល់ថ្ងៃទី៣១-៨-២០០៤ ទទួលបានសំណុំរឿងព្រហ្មទណ្ឌចំនួន១០៦៤ រឿង ក្នុងនោះ មានការឃុំខ្លួនពិរុទ្ធជនលើសកំណត់ច្បាប់ចំនួន៩២ នាក់ មានប្រុសចំនួន ៦៥ នាក់ ស្ត្រី០២ នាក់ កុមារចំនួន ២៥ នាក់ ។

ពាក់ព័ន្ធករណីខាងលើនេះ ក្រសួងសូមធ្វើការរំលឹកដល់លោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញា ដូចខាងក្រោម :

តាមបញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី០៨-០៣-១៩៩៣ និងបញ្ញត្តិមាត្រា ១៤ ត្រង់ចំណុចទី ៤ នៃច្បាប់ស្តីពីប្រព័ន្ធតុលាការ ក្នុងសម័យអន្តរកាល ចុះថ្ងៃទី១០-០៨-១៩៩២ ដែលមានចែងអោយឃុំខ្លួនជនត្រូវចោទ មុនពេលជំនុំជម្រះយ៉ាងយូរត្រឹម០៦ ខែ ប៉ុណ្ណោះ ។ តែសព្វថ្ងៃនេះតុលាការក្រុងភ្នំពេញ បានឃុំខ្លួនជនត្រូវចោទលើសពី០៦ ខែ ដែលជាហេតុធ្វើអោយផ្ទុយនឹងបញ្ញត្តិខាងលើនេះជាពិសេសអស់លោកកំពុងតែរំលោភលើសិទ្ធិបុគ្គលតាមមាត្រា៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលទៀតផង ។

ម្យ៉ាងទៀត មានមតិខ្លះលើកឡើងថា នៅតុលាការក្រុងភ្នំពេញ មិនបានគោរពវិន័យក្នុងម៉ោងការងាររដ្ឋបាលដែលខ្លួនបានបំពេញតាមរបបរដ្ឋបាលកំណត់ទេ មានលោកចៅក្រម ព្រះរាជអាជ្ញារង ក្រឡាបញ្ជីខ្លះ មកធ្វើការយឺតយ៉ាវ ហើយចេញមុនម៉ោង មានមន្ត្រីខ្លះអវត្តមាន ដែលជាមូលហេតុធ្វើអោយមានការកកស្ទះសំណុំរឿងដាក់សំណុំរឿងទៅជំនុំជម្រះ មិនទាន់ពេលវេលា ជាពិសេសពេលដាក់សំណុំរឿងជំនុំជម្រះត្រូវបានលើក ឬពន្យាពេលសវនាការ បណ្តាលមកពីករណីខាងលើនេះ ។

ទន្ទឹមនឹងនេះដែរ តុលាការក្រុងភ្នំពេញ ក៏ដូចសាលាឧទ្ធរណ៍ និងតុលាការកំពូល មានការយឺតយ៉ាវក្នុងការផ្តល់សាលក្រម សាលដីកា ទៅអោយមន្ត្រីពន្ធនាគារ ដែលជាហេតុធ្វើអោយមន្ត្រីពន្ធនាគា មិនអាចគ្រប់គ្រងនិងតាមដានការបន្ធូរបន្ថយទោស និងលើកលែងទោសត្រូវធ្វើ០៣ ដងក្នុងមួយឆ្នាំរបស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាយើង ។

អាស្រ័យហេតុនេះ ក្រសួងអោយលោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញា ជំរុញចៅក្រមស៊ើបអង្កេត ចៅក្រមជំនុំជម្រះព្រះរាជអាជ្ញារង ក្រឡាបញ្ជី និងមន្ត្រីទាំងអស់អោយយកចិត្តទុកដាក់ខ្លាំងបំផុត និងជាបន្ទាន់ក្នុងស្មារតីទទួលខុសត្រូវ លើកយកករណីខាងលើ មកចាត់ការទៅតាមនីតិវិធីនៃច្បាប់ជាធរមាន ។

សូមលោកទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៤

**ជ.រដ្ឋមន្ត្រី**

**ទូត លុច**

<u>ចម្លងជូន</u>

-តុលាការកំពូល

-សាលាឧទ្ធរណ៍

-ពន្ធនាគារម១ (ព្រៃស)

-ដើម្បីជូនជ្រាប